# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៨៩ ប្រក.កសក

# ប្រកាស
## ស្តីពី
## ការបង្កើត និងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ប្រាំបីមុម ស្ថិតនៅភូមិត្រពាំងក្រើញ ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ២១៩ ប្រក.កសក. ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ
- បានឃើញប្រកាសលេខ៦០៩ ប្រក.កសក ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ស្តីពីការប្តូរឈ្មោះមន្ទីរកសិកម្ម រាជធានី ខេត្ត និងការដាក់បញ្ចូលខណ្ឌរដ្ឋបាលព្រៃឈើ និងខណ្ឌរដ្ឋបាលជលផលឲ្យស្ថិតក្រោមមន្ទីរកសិកម្មរាជធានី ខេត្ត
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតតំបន់ព្រៃសហគមន៍ប្រាំបីមុម សម្រាប់ធ្វើការគ្រប់គ្រងប្រកបដោយនិរន្តរភាពតាមលក្ខណៈសហគមន៍ព្រៃឈើ មានទីតាំងស្ថិតនៅភូមិត្រពាំងក្រើញ ឃុំប្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ។

**ប្រការ២ .-**

ការបង្កើតតំបន់ព្រៃសហគមន៍នេះមានគោលដៅ៖

- គ្រប់គ្រង ប្រើប្រាស់ ការពារ ថែរក្សា អភិរក្សជីវចម្រុះ និងអភិវឌ្ឍន៍ព្រៃសហគមន៍ឲ្យមានចីរភាព
- ប្រើប្រាស់ផល អនុផលព្រៃឈើជាលក្ខណៈប្រពៃណីសម្រាប់ការរស់នៅ ទំនៀមទម្លាប់ និងជំនឿសាសនា
- ទាញយកផល អនុផលព្រៃឈើ ស្របតាមលទ្ធភាពធនធាន និងសក្តានុពលព្រៃសហគមន៍
- គាំទ្រដល់គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រ។

**ប្រការ៣ .-**

តំបន់ព្រៃសហគមន៍ប្រាំបីមុម មានផ្ទៃក្រឡាសរុបទំហំ៩៣៧ (ប្រាំបួនរយសាមសិបប្រាំពីរ) ហិកតា ដូចមានផែនទីភ្ជាប់មកជាឧបសម្ព័ន្ធនៃប្រកាសនេះ និងមាននិយាមកាចំណុចគោល (Datum: WGS១៩៨៤) ដូចខាងក្រោម៖

| ចំណុចនិយាមកាព្រៃសហគមន៍ | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) | ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) | ចំណុចគោល | អាប់ស៊ីស (X) | អរដោនេ (Y) |
| 1 | 426165 | 1297030 | 23 | 430392 | 1295900 | 45 | 428138 | 1294750 |
| 2 | 426338 | 1297030 | 24 | 430416 | 1295830 | 46 | 427950 | 1294820 |
| 3 | 426374 | 1297020 | 25 | 430354 | 1295730 | 47 | 427836 | 1294860 |
| 4 | 426754 | 1297100 | 26 | 430306 | 1295610 | 48 | 427715 | 1294880 |
| 5 | 426798 | 1296960 | 27 | 430283 | 1295480 | 49 | 427589 | 1294900 |
| 6 | 427183 | 1296930 | 28 | 430278 | 1295420 | 50 | 427393 | 1294860 |
| 7 | 427383 | 1296770 | 29 | 430258 | 1295140 | 51 | 427098 | 1294780 |
| 8 | 427477 | 1296790 | 30 | 430529 | 1294780 | 52 | 426840 | 1294790 |
| 9 | 427968 | 1296720 | 31 | 430596 | 1294730 | 53 | 426676 | 1294940 |
| 10 | 428160 | 1296810 | 32 | 430626 | 1294540 | 54 | 426620 | 1294960 |
| 11 | 428667 | 1296780 | 33 | 430546 | 1294560 | 55 | 426475 | 1294930 |
| 12 | 428834 | 1296790 | 34 | 430353 | 1294530 | 56 | 426273 | 1294870 |
| 13 | 429106 | 1296860 | 35 | 430195 | 1294550 | 57 | 426185 | 1294810 |
| 14 | 429199 | 1296880 | 36 | 429796 | 1294650 | 58 | 425990 | 1294900 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 15 | 429428 | 1296870 | 37 | 429493 | 1294610 | 59 | 425682 | 1294920 |
| 16 | 429774 | 1296840 | 38 | 429189 | 1294710 | 60 | 425731 | 1295440 |
| 17 | 429733 | 1296540 | 39 | 429056 | 1294730 | 61 | 425780 | 1295960 |
| 18 | 429827 | 1296480 | 40 | 428852 | 1294780 | 62 | 425691 | 1296090 |
| 19 | 429885 | 1296450 | 41 | 428683 | 1294770 | 63 | 425615 | 1296130 |
| 20 | 429985 | 1296410 | 42 | 428560 | 1294790 | 64 | 425589 | 1296280 |
| 21 | 430041 | 1296390 | 43 | 428390 | 1294730 | 65 | 425767 | 1296560 |
| 22 | 430252 | 1296090 | 44 | 428243 | 1294740 | | | |

**ប្រការ៤ .—**

ដំណើរការរៀបចំ និងការប្រព្រឹត្តទៅនៃសហគមន៍ព្រៃឈើក្នុងតំបន់ព្រៃសហគមន៍នៃប្រកាសនេះ ត្រូវអនុវត្តតាមនីតិវិធីដូចបានកំណត់នៅក្នុងច្បាប់ស្តីពីព្រៃឈើ អនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ និងប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍ព្រៃឈើ។

**ប្រការ៥ .—**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦ .—**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលពាក់ព័ន្ធ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ៣ កើត ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ មេសា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងរ៉ែនិងថាមពល
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តកំពង់ស្ពឺ
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ ១៨៩ ប្រក.កសក ចុះថ្ងៃ អង្គារ ០៣ រោច ខែ ចេត្រ ឆ្នាំ រកា នព្វស័ក ព.ស ២៥៦១ ត្រូវនឹងថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៨

## ផែនទីទីតាំងព្រៃសហគមន៍ត្រាំបីមុម ស្ថិតនៅភូមិត្រពាំងក្រើញ ឃុំត្រាំបីមុម ស្រុកថ្ពង ខេត្តកំពង់ស្ពឺ







| ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ | ចំណុចគោល | អាប់ស៊ីស | អរដោនេ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 426165 | 1297030 | 12 | 428834 | 1296790 | 23 | 430392 | 1295900 | 34 | 430353 | 1294530 | 45 | 428138 | 1294750 | 56 | 426273 | 1294870 |
| 2 | 426338 | 1297030 | 13 | 429106 | 1296860 | 24 | 430416 | 1295830 | 35 | 430195 | 1294550 | 46 | 427950 | 1294820 | 57 | 426185 | 1294810 |
| 3 | 426374 | 1297020 | 14 | 429199 | 1296880 | 25 | 430354 | 1295730 | 36 | 429796 | 1294650 | 47 | 427836 | 1294860 | 58 | 425990 | 1294900 |
| 4 | 426754 | 1297100 | 15 | 429428 | 1296870 | 26 | 430306 | 1295610 | 37 | 429493 | 1294610 | 48 | 427715 | 1294880 | 59 | 425682 | 1294920 |
| 5 | 426798 | 1296960 | 16 | 429774 | 1296840 | 27 | 430283 | 1295480 | 38 | 429189 | 1294710 | 49 | 427589 | 1294900 | 60 | 425731 | 1295440 |
| 6 | 427183 | 1296930 | 17 | 429733 | 1296540 | 28 | 430278 | 1295420 | 39 | 429056 | 1294730 | 50 | 427393 | 1294860 | 61 | 425780 | 1295960 |
| 7 | 427383 | 1296770 | 18 | 429827 | 1296480 | 29 | 430258 | 1295140 | 40 | 428852 | 1294780 | 51 | 427098 | 1294780 | 62 | 425691 | 1296090 |
| 8 | 427477 | 1296790 | 19 | 429885 | 1296450 | 30 | 430529 | 1294780 | 41 | 428683 | 1294770 | 52 | 426840 | 1294790 | 63 | 425615 | 1296130 |
| 9 | 427968 | 1296720 | 20 | 429985 | 1296410 | 31 | 430596 | 1294730 | 42 | 428560 | 1294790 | 53 | 426676 | 1294940 | 64 | 425589 | 1296280 |
| 10 | 428160 | 1296810 | 21 | 430041 | 1296390 | 32 | 430626 | 1294540 | 43 | 428390 | 1294730 | 54 | 426620 | 1294960 | 65 | 425767 | 1296560 |
| 11 | 428667 | 1296780 | 22 | 430252 | 1296090 | 33 | 430546 | 1294560 | 44 | 428243 | 1294740 | 55 | 426475 | 1294930 | | | |

### សញ្ញាសម្គាល់

- • ចំណុចគោល
- ▭ ព្រំប្រទល់ព្រៃសហគមន៍

### គម្របព្រៃឈើឆ្នាំ២០១៤

ព្រៃល្បោះ

ដីគ្មានគម្របព្រៃឈើ

COORDINATE SYSTEM
Projection : UTM
Zone : 48
Horizontal Datum : WGS1984
UTMGrid : 1km

N

មាត្រដ្ឋាន ១ : ២៥.០០០

0 0.5 1 Km